ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

គណៈកម្មការជ្រើសរើសពលទាហាន

បំពេញក្របខណ្ឌឲ្យយោធភូមិភាគទី១

កងទ័ពជើងគោក

លេខ: ៤៣៣/ស.ជណ/២០១៧

ថ្ងៃ ព្រហស្បតិ៍ ១២កើត ខែ មិគសិរ ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពីៈ ការប្រកាសលទ្ធផលជ្រើសរើសពលទាហានបំពេញក្របខណ្ឌ នៅយោធភូមិភាគទី១ កងទ័ពជើងគោក និងការប្រមូលផ្តុំពលទាហាន

គណៈកម្មការជ្រើសរើសពលទាហានបំពេញក្របខណ្ឌឲ្យយោធភូមិភាគទី១ កងទ័ពជើងគោក មានកិត្តិយស សូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ ដែលបានដាក់ពាក្យបម្រើការងារជាយោធិន នៃកងយោធពលខេមរភូមិន្ទឲ្យបានជ្រាបថា៖ គណៈកម្មការជ្រើសរើសពលទាហាន នឹងធ្វើការប្រកាសលទ្ធផលជាផ្លូវការ ស្តីពីការជ្រើសរើសពលទាហានបំពេញក្របឲ្យយោធភូមិភាគទី១ កងទ័ពជើងគោក និងធ្វើការប្រមូលផ្តុំពលទាហានទៅតាមពេលវេលា និងទីកន្លែងដែលបានកំណត់ដូចតទៅ៖

១. នឹងបិតប្រកាសលទ្ធផលឈ្មោះបេក្ខជនត្រូវបានជ្រើសរើស ចាប់ពីថ្ងៃទី១១-១៧ ខែធ្នូ ឆ្នាំ២០១៧ នៅតាមបណ្តាការិយាល័យដែលបេក្ខជនបានដាក់ពាក្យ

២. ចំពោះបេក្ខជនមានឈ្មោះក្នុងប្រកាសលទ្ធផល សូមទៅបង្ហាញខ្លួននៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ជាកំហិត នៅទីបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តដែលបេក្ខជនបានដាក់ពាក្យ និងដោយឡែកសម្រាប់រាជធានីភ្នំពេញ គឺនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

អាស្រ័យដូចជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ មេត្តាជ្រាប និងអញ្ជើញទៅពិនិត្យឈ្មោះរបស់ខ្លួនដែលនឹងត្រូវបិតផ្សាយឲ្យបានទាន់ពេលវេលា ដើម្បីត្រៀមប្រមូលផ្តុំទៅតាមការកំណត់របស់គណៈកម្មការ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងក្រុមការងារ តាមទូរស័ព្ទលេខ 085333944 / 085222744 / 0972666241 / 0972666240 / 086847300 / 086685570 ។

គណៈកម្មការជ្រើសរើសពលទាហាន